ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ១៩/០៩- ហ្គាឡាស៊ី**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **ឈើវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ហ្គាឡាស៊ី**

អាសយដ្ឋាន : ភូមិអូរអណ្តូង សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩២៨ ២២៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក : គ្មាន

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : **សហជីពសេរីកម្មករ នៃក្រុមហ៊ុន ហ្គាឡាស៊ី**

អាសយដ្ឋាន : ភូមិអូរអណ្តូង សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨៨០ ០៣៩ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោកស្រី យ៉ាង សុភ័ណ្ឌ | មន្ត្រីសហជីពសេរីកម្មករ |
| ២- លោក លន់ លីន | កម្មករ |
| ៣- លោក រ៉េត លាប | កម្មករ |
| ៤- លោក ជូន ចន្ថា | កម្មករ |



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh - Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org- Website: www.arbitrationcouncil.org

៥-  លោក ឡាយ សុខា                    កម្មករ

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករចំនួន ១៨ នាក់ចូលធ្វើការជាធម្មតាវិញ។

២- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពចំនួនប្រាំមួយដុល្លារ ដល់កម្មករគ្រប់គ្នា។

៣- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ ៥០ ភាគរយ សម្រាប់កម្មការិនីឈប់សម្រាកលំហែមាតុភាព។

៤- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនមានបន្ទប់ពេទ្យ និងគ្រូពេទ្យសម្រាប់ព្យាបាលជំងឺកម្មករ-កម្មការិនី។

៥- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនត្រូវសំអាតបន្ទប់ទឹកឱ្យមានអនាម័យ និងមានទឹកប្រើប្រាស់ ឱ្យបានគ្រប់គ្រាន់។

៦- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនត្រូវចេញថ្លៃព្យាបាលដល់កម្មករ-កម្មការិនី ពេលមានគ្រោះថ្នាក់ការងារ។

៧- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនត្រូវមានទឹកបរិភោគឱ្យបានគ្រប់គ្រាន់ និងមានអនាម័យត្រឹមត្រូវ។

៨- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនត្រូវផ្តល់ការឈប់សម្រាកប្រចាំឆ្នាំចំនួន ១៨ ថ្ងៃ ក្នុងមួយឆ្នាំ ជូនកម្មករ-កម្មការិនី។

៩- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនត្រូវបញ្ចូលកម្មករ-កម្មការិនី ដែលធ្វើការរយៈពេលយូរ ជាកម្មករពេញសិទ្ធិ។

១០- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនត្រូវបើកប្រាក់ឈ្នួល ជូនកម្មករ-កម្មការិនី យោងប្រកាសថ្មី មួយខែពីរដង។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិក

ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០៨០/០៩ ក.ប/អក/វ.ក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩។

## សវនាការ និង សវនាការមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :**

- សវនាការលើកទី ១ : ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ (វេលាម៉ោង ០៩:០០ នាទី ព្រឹក) ។
- សវនាការលើកទី ២ : ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក) ។
- សវនាការលើកទី ៣ : ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩ (វេលាម៉ោង ០២:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៨ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងរបស់កម្មករនិយោជិតទាមទារក្រុមហ៊ុនឱ្យកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ ជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៩ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេលើការទាមទារចំនួន ១០ចំណុច។ ចំណុចមិនសះជាចំនួន ១០ ចំណុចនេះ ត្រូវបានបញ្ជូនមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១០ ចំណុចនេះ លើកទី១ នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ (វេលាម៉ោង ០៩:០០ នាទី ព្រឹក) ដោយមានវត្តមានភាគីកម្មករនិយោជិត ចំណែកឯភាគីនិយោជក អវត្តមាន ហើយភាគីកម្មករនិយោជិតបានស្នើសុំឱ្យរៀបចំសវនាការលើកទី២ ទៀត ព្រោះពួកគេចង់ជួបចរចាជាមួយនិយោជក។ នៅថ្ងៃសវនាការលើកទី២ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក) ភាគីកម្មករនិយោជិត មានវត្តមាន ចំណែកឯភាគីនិយោជក នៅតែអវត្តមានដដែល ដូច្នេះ នៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ នេះដដែល ភាគីកម្មករនិយោជិត បានធ្វើលិខិតសុំព្យួរសំណុំរឿង ដើម្បីចរចាជាមួយភាគីនិយោជក ហើយម្យ៉ាងទៀត ក្រុមហ៊ុនកំពុងស្ថិតក្នុងដំណាក់កាលព្យួរការងារ។

នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ លេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរស័ព្ទសួរភាគីអំពីលទ្ធផលនៃការចរចា ប៉ុន្តែមិនទាន់មានលទ្ធផលអ្វីទេ ព្រោះក្រុមហ៊ុនកំពុងស្ថិតក្នុងដំណាក់កាលព្យួរការងារដដែល ។ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរស័ព្ទទំនាក់ទំនងទៅភាគីម្តងទៀត អំពីលទ្ធផលនៃការចរចា ប៉ុន្តែមិនទាន់មានលទ្ធផលអ្វីទេ ទោះបីក្រុមហ៊ុនចាប់ផ្តើមមានការងារធ្វើជាបណ្តើរៗ ក៏ដោយ ។ នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៩ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរស័ព្ទទំនាក់ទំនងភាគីម្តងទៀត អំពីលទ្ធផលនៃការចរចា ប៉ុន្តែនៅតែគ្មានលទ្ធផលដដែល ។ ហេតុនេះហើយ ភាគីកម្មករនិយោជិតស្នើឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលកំណត់ថ្ងៃសវនាការលើសំណុំរឿងនេះ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេច បើកសវនាការលើកទី៣លើសំណុំរឿងនេះ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩ (វេលាម៉ោង ០២:០០ នាទី រសៀល) ប៉ុន្តែនៅថ្ងៃសវនាការ ភាគីទាំងពីរអវត្តមាន ដោយគ្មានមូលហេតុត្រឹមត្រូវទេ ។ ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាង ក្រោម:

**ឥស្សុតាខ**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ឧត្តុតាខ ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- ពាក្យសុំព្យួរសំណុំរឿង លេខ ១៩/០៩-ហ្គាឡាស៊ី នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធ្វើការចចារជាមួយភាគីនិយោជក ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្គាឡាស៊ី លេខ ០៨០/០៩ ក.ប/អក/វក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ហ្គាឡាស៊ី ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៩ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ០៨០ កប/អក/វក/លកអ. ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។

២- លិខិតអញ្ជើញភាគីសហជីពកម្មករនិយោជិត ចូលរួមសវនាការលើកទី១ លេខ ០៨១ កប/អក/វក/លកអ. ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ១១១ កប/អក/វក/លកអ. ចុះថ្ងៃទី

២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩។

៤- លិខិតអញ្ជើញភាគីសហជីពកម្មករនិយោជិត ចូលរួមសវនាការលើកទី២ លេខ ១១២ កប/អក/វក/លកអ. ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩។

៥- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី៣ លេខ ២៦៨ កប/អក/វក/លកអ. ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៩។

៦- លិខិតអញ្ជើញភាគីសហជីពកម្មករនិយោជិត ចូលរួមសវនាការលើកទី៣ លេខ ២៦៩ កប/អក/វក/លកអ. ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

**ការរកឃើញអង្គហេតុ:**

គ្មានការរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារទាំងនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិត និងភាគីនិយោជកអវត្តមាននៅក្នុងថ្ងៃសវនាការ ដោយមិនបានផ្តល់មូលហេតុណាមួយឡើយ។

**ហេតុផលក្នុងការធ្វើសេចក្តីសំរេច :**

តាមប្រការ ២១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ *" ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ "*។

បន្ថែមពីនេះទៀត វិធាន ៤.៧ នៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ចែងថា *" ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមល័ក្ខខ័ណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន "*។

ផ្អែកលើប្រការ ២១ និង វិធាន ៤.៧ ខាងលើនេះ នៅក្នុងសេចក្តីបង្គាប់លេខ ៣០/០៥-មូរៀ. លេខ ១៦/០៧-ឡូទូសតី. លេខ ២៧/០៧-អ៊ីម និង វ៉េ ៣. លេខ ៩៥/០៨-យ៉ុង វ៉ា ទី១. លេខ ១៣២/០៨-ជី អេច ជី លេខ ១៣៨/០៨-ម៉ាលីន. លេខ ១៥១/០៨-វិល សិន. លេខ ០៩/០៩-នីមបឹស ថិចថាយ៉េ. និង លេខ ២៤/០៩-

ម៉ាកលីន ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញមុនពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ។ លក្ខខណ្ឌទី២ គឺភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺភាគីមិនបានផ្តល់មូលហេតុ សម្រាប់ ការមិនបង្ហាញខ្លួន។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីត្រូវបានបំពេញដែរឬអត់?

**លក្ខខណ្ឌទី ១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ**

ដូចដែលបានបញ្ជាក់ក្នុងវិធាន ៤.៧ ខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់ ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីវិវាទត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរអាជ្ញាកណ្តាល។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើលិខិតអញ្ជើញជាផ្លូវការទៅកាន់ភាគីទាំងពីរ។ លិខិតអញ្ជើញទាំងនេះ ត្រូវបានធ្វើឡើងដោយនីតិវិធីជាប្រចាំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងទៅកាន់ភាគីអំពីកាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងនៃថ្ងៃសវនាការតាមរយៈលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរ និង តាមទូរស័ព្ទ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី២: ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ប្រការ ១៩ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ ។"*

បន្ថែមពីនេះទៀត ប្រការ២០ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ក៏បានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ..... ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ។"*

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិត និងភាគីនិយោជក មិនបានចូលរួមសវនាការ ហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាង (ដូចជា ខាងសហព័ន្ធ សហជីព ឬ មេធាវី) ដើម្បីតំណាងពួកគេនៅក្នុងសវនាការនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌ ទី២ ក៏ត្រូវបានបំពេញដែរ។

THE ARBITRATION COUNCIL

**លក្ខខណ្ឌទី ៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ដូចដែលបានបញ្ជាក់ក្នុងប្រការ ២១ នៃប្រកាសខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិត និងនិយោជក គឺអវត្តមានទាំងពីរ និងមិនបានផ្តល់មូលហេតុត្រឹមត្រូវណាមួយដល់ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល អំពីការមិនចូលរួមសវនាការនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌ ទី៣ ក៏ត្រូវបានបំពេញដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បិទសំណុំរឿងលេខ ១៩/០៩- ហ្គាឡាស៊ី នេះ ដោយភាគីកម្មករនិយោជិត និង និយោជកមិនមានវត្តមាននៅពេលសវនាការលើកទី៣។

ដោយសំអាងលើអង្គហេតុ និង អង្គច្បាប់ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញ សេចក្តីបង្គាប់ដូចតទៅ:

## សម្រេច និង បង្គាប់

បិទសំណុំរឿងលេខ ១៩/០៩- ហ្គាឡាស៊ី។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈឹម គិររម្យ**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------------